**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត**

**ប្រ.ក/លេខ០១.១៩៤/០៧ គ.ជ.ប.អគ្គ.ពស** ភ្នំពេញ ថ្ងៃទី ១៩ ខែ មករា ឆ្នាំ ២០០៧

# បេក្ខជនឈរឈ្មោះបោះឆ្នោតរបស់គណបក្សនរោត្តម រណឫទ្ធិ និងគណបក្សរណសិរ្សសង្គមជាតិនិយម នៅខេត្តបាត់ដំបង បានសុំឱ្យ គ.ជ.ប លុបឈ្មោះចេញពីបេក្ខជនឈរឈ្មោះបោះឆ្នោត

នៅថ្ងៃទី ១៨ ខែ មករា ឆ្នាំ ២០០៧ គ.ជ.ប បានសម្រេចលុបឈ្មោះបេក្ខជនឈរឈ្មោះបោះឆ្នោត ចំនួន ៧៨រូប ចេញពីបញ្ជីបេក្ខជនឈរឈ្មោះបោះឆ្នោតនៃគណបក្សនយោបាយចំនួន ២ នៅឃុំចំនួន ១០ ក្នុងខេត្តបាត់ដំបង តាមការស្នើសុំរបស់បេក្ខជនផ្ទាល់ ។

បន្ទាប់ពី គ.ជ.ប បានទទួលពាក្យបណ្តឹងរបស់បេក្ខជនឈរឈ្មោះបោះឆ្នោត ១០២រូប សុំឱ្យ គ.ជ.ប លុបឈ្មោះចេញពីបញ្ជីបេក្ខជននៃគណបក្សនយោបាយ គ.ជ.ប បានចាត់ឱ្យមន្ត្រីជំនាញចុះស្រាវជ្រាវស៊ើបអង្កេតដល់ទីកន្លែង ។ ហើយបេក្ខជន ៧៨រូប បានមកបំភ្លឺបន្ថែមដោយផ្ទាល់នៅចំពោះមុខ គឃ/សប ដោយនៅតែរក្សាពាក្យបណ្តឹងសុំឱ្យ គ.ជ.ប លុបឈ្មោះដដែល ចំណែកបេក្ខជន ចំនួន ២៤រូប ទៀតអវត្តមាន មិនបានចូលខ្លួនមកបំភ្លឺតាមពាក្យបណ្តឹងរបស់ខ្លួនឡើយ ។ ជាលទ្ធផល គ.ជ.ប ក៏សម្រេចលុបឈ្មោះបេក្ខជនចំនួន **៧៨រូប** ក្នុងនោះរួមមាន **៧៣រូប** បានលុបឈ្មោះចេញពីបញ្ជីបេក្ខជនឈរឈ្មោះបោះឆ្នោតនៃគណបក្សនរោត្តម រណឫទ្ធិ និង **៥រូប**ទៀត បានលុបឈ្មោះចេញពីបញ្ជីបេក្ខជនឈរឈ្មោះបោះឆ្នោតនៃគណបក្សរណសិរ្សសង្គមជាតិនិយម ។

ឯកឧត្តម ទេព នីថា អគ្គលេខាធិការ គ.ជ.ប បានបញ្ជាក់ថា ការលុបឈ្មោះបេក្ខជននៅក្រោយការបិទផ្សាយបញ្ជីបេក្ខជនដំបូងនេះ មិនធ្វើឱ្យប៉ះពាល់ដល់បញ្ជីបេក្ខជននៃសាមី គណបក្សនយោបាយឡើយ ។